**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## សន្និសីទថ្នាក់ជាតិ ស្តីពីសេដ្ឋកិច្ចការងារ ឆ្នាំ២០២៦

## ក្រោមប្រធានបទ «បរិវត្តកម្មទីផ្សារការងារ និងអន្តរកាលសេដ្ឋកិច្ចកម្ពុជា ក្នុងបរិបទអាស៊ាន៖ ជំនាញ បច្ចេកវិទ្យា និងភាពធន់ ក្នុងដំណាក់កាលភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកល»

ប្រទេសកម្ពុជា ក៏ដូចជាអាស៊ានកំពុងឈានចូលក្នុងដំណាក់កាលនៃបរិវត្តកម្មទីផ្សារការងារយ៉ាងឆាប់រហ័ស ដែលជំរុញដោយបរិវត្តកម្មបច្ចេកវិទ្យា បម្រែបម្រួលប្រជាសាស្ត្រ ការប្រែប្រួលអាកាសធាតុ ការរៀបចំរចនាសម្ព័ន្ធខ្សែច្រវាក់ផ្គត់ផ្គង់ឡើងវិញ និងការវិវត្តថ្មីនៃទម្រង់ការងារ។ ទន្ទឹមនឹងនេះ កម្ពុជាកំពុងត្រៀមខ្លួនសម្រាប់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ដែលតម្រូវឱ្យមានគោលនយោបាយទីផ្សារការងារ ការអភិវឌ្ឍជំនាញ និងការគាំពារសង្គមដែលមានភាពបត់បែន បរិយាបន្ន និងផ្អែកលើភស្តុតាង។ ក្នុងន័យនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងរៀបចំសន្និសីទថ្នាក់ជាតិ ស្តីពីសេដ្ឋកិច្ចការងារ ឆ្នាំ២០២៦ ដែលនឹងប្រមូលផ្តុំអ្នករៀបចំគោលនយោបាយ ដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ និស្សិត និងភាគីពាក់ព័ន្ធ ជាតិនិងអន្តរជាតិ ដើម្បីរួមចំណែកពិភាក្សា និងស្វែងរកដំណោះស្រាយជាក់ស្តែង។

ក្រសួងសូមអញ្ជើញអ្នករៀបចំគោលនយោបាយ ដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ និស្សិត និងភាគីពាក់ព័ន្ធជាតិនិងអន្តរជាតិ ចូលរួមដាក់អត្ថបទស្រាវជ្រាវពាក់ព័ន្ធនឹងសន្និសីទថ្នាក់ជាតិនេះ ដែលជាធាតុចូលបន្ថែមសម្រាប់ការពិភាក្សា និងការរៀបចំគោលនយោបាយ ដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ច និងទីផ្សារការងារដែលមានភាពធន់ក្នុងដំណាក់កាលភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកល។

សម្រាប់ លោក លោកស្រី ដែលមានចំណាប់អារម្មណ៍ អាចស្វែងរកព័ត៌មានបន្ថែមតាមរយៈ QR Code ខាងក្រោម ឬតំណភ្ជាប់ https://lec.events ឬសូមដាក់អត្ថបទស្រាវជ្រាវតាមរយៈអ៊ីម៉ែល sokunthea.sok@mlvt.gov.kh។

**កាលបរិច្ឆេទសំខាន់ៗ៖**

- ការផុតកំណត់នៃការដាក់អត្ថបទស្រាវជ្រាវសង្ខេប៖ **ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៦**
- ការផុតកំណត់នៃការដាក់អត្ថបទស្រាវជ្រាវទាំងមូល៖ **ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៦**
- ការរៀបចំសន្និសីទថ្នាក់ជាតិ ស្តីពីសេដ្ឋកិច្ចការងារ ឆ្នាំ២០២៦៖ **ថ្ងៃទី១១-១២ ខែវិច្ឆិកា ឆ្នាំ២០២៦។**

ថ្ងៃ ចន្ទ ៤រោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែសីហា ឆ្នាំ២០២៦

**ស្កេនទីនេះដើម្បីទទួលបានព័ត៌មានបន្ថែម**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩